**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងបរិស្ថាន**
លេខ :...០៩១/២៤.ក....ប.ស្ថ

# ប្រកាស
## ស្តីពី
## ការទទួលស្គាល់សហគមន៍តំបន់ការពារធម្មជាតិ «ប្រាសាទឈើទាលកោង» នៃដែនជម្រកសត្វព្រៃ «ព្រៃឡង់» ស្ថិតនៅភូមិឆ្នា ឃុំឆ្នា ស្រុកជ័យសែន ខេត្តព្រះវិហារ

## រដ្ឋមន្ត្រីក្រសួងបរិស្ថាន

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៨១៨/៩២៥ ចុះថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/២១ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងបរិស្ថាន
- បានឃើញព្រះរាជក្រមលេខ នស/រកម/០២០៨/០០៧ ចុះថ្ងៃទី១៥ ខែកុម្ភៈ ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីតំបន់ការពារធម្មជាតិ
- បានឃើញព្រះរាជក្រឹត្យចុះថ្ងៃទី០១ ខែវិច្ឆិកា ឆ្នាំ១៩៩៣ ស្តីពីការគ្រប់គ្រងតំបន់ការពារធម្មជាតិ
- បានឃើញអនុក្រឹត្យលេខ ១៣៥ អនក្រ.បក ចុះថ្ងៃទី០៥ ខែកក្កដា ឆ្នាំ២០១៦ របស់រាជរដ្ឋាភិបាល ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងបរិស្ថាន
- បានឃើញអនុក្រឹត្យលេខ ៧៤ អនក្រ.បក ចុះថ្ងៃទី០៩ ខែឧសភា ឆ្នាំ២០១៦ ស្តីពីការបង្កើតដែនជម្រកសត្វព្រៃ «ព្រៃឡង់»
- យោងតាមតម្រូវការចាំបាច់របស់ក្រសួងបរិស្ថាន

## សម្រេច

**ប្រការ១._**

ត្រូវបានទទួលស្គាល់សហគមន៍តំបន់ការពារធម្មជាតិ **«ប្រាសាទឈើទាលកោង»** នៃដែនជម្រកសត្វព្រៃ «ព្រៃឡង់» ស្ថិតនៅភូមិឆ្នា ឃុំឆ្នា ស្រុកជ័យសែន ខេត្តព្រះវិហារ។

**ប្រការ២._**

សហគមន៍តំបន់ការពារធម្មជាតិ **«ប្រាសាទឈើទាលកោង»** នៃដែនជម្រកសត្វព្រៃ «ព្រៃឡង់» មានផ្ទៃដីសរុបទំហំ **៧២៨.៦២ ហិកតា** (ប្រាំពីររយម្ភៃប្រាំបីកន្លះសញ្ញាហុកសិបពីរហិកតា) ដូចមានផែនទីភ្ជាប់ជាឧបសម្ព័ន្ធ កំណត់ដោយចំណុចគោល ដែលមាននិយាមកា (Datum: WGS1984) ដូចក្នុងតារាងខាងក្រោម៖



អគារមរតកតេជោ ដីឡូលេខ503 ផ្លូវកាត់ស៊ីអមមាត់ទន្លេបាសាក់ សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន ភ្នំពេញ ទូរស័ព្ទ: ០២៣ ២១៣ ៩០៨, ០២៣ ២២០ ៣៦៩ ទូរសារ: ០២៣ ២១២ ៥៤០

| ID | X | Y | ID | X | Y |
|---|---|---|---|---|---|
| 1 | 557245 | 1505801 | 6 | 561572 | 1506026 |
| 2 | 557395 | 1505961 | 7 | 561703 | 1504569 |
| 3 | 557469 | 1505969 | 8 | 561501 | 1503875 |
| 4 | 557704 | 1506070 | 9 | 559948 | 1504011 |
| 5 | 559342 | 1506208 | 10 | 557334 | 1505450 |

**ប្រការ៣._**

ការរៀបចំបង្កើតសហគមន៍តំបន់ការពារធម្មជាតិ **«ប្រាសាទឈើទាលកោង»** ក្នុងគោលបំណងបង្កើនការចូលរួមគ្រប់គ្រងប្រើប្រាស់ធនធានធម្មជាតិប្រកបដោយចីរភាព និងរួមចំណែកលើកកម្ពស់ជីវភាពសហគមន៍មូលដ្ឋានស្របតាមគោលនយោបាយរបស់រាជរដ្ឋាភិបាល។

**ប្រការ៤._**

សហគមន៍តំបន់ការពារធម្មជាតិ **«ប្រាសាទឈើទាលកោង»** នៃដែនជម្រកសត្វព្រៃ «ព្រៃឡង់» ត្រូវចុះកិច្ចព្រមព្រៀងជាមួយអគ្គនាយកដ្ឋានសហគមន៍មូលដ្ឋាន នៃក្រសួងបរិស្ថាន។ សហគមន៍តំបន់ការពារធម្មជាតិ **«ប្រាសាទឈើទាលកោង»** ត្រូវរៀបចំលក្ខន្តិកៈ និងផែនការគ្រប់គ្រងស្របតាមច្បាប់ស្តីពីតំបន់ការពារធម្មជាតិ។

**ប្រការ៥._**

បទប្បញ្ញត្តិទាំងឡាយណា ដែលផ្ទុយនឹងប្រកាសនេះ ត្រូវទុកជានិរាករណ៍។

**ប្រការ៦._**

នាយកខុទ្ទកាល័យរដ្ឋមន្ត្រី អគ្គលេខាធិការ នៃអគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាជាតិអភិវឌ្ឍន៍ដោយចីរភាព គ្រប់អគ្គនាយក នៃអគ្គនាយកដ្ឋានចំណុះក្រសួង អគ្គាធិការ នៃអគ្គាធិការដ្ឋាន ប្រធាននាយកដ្ឋានពាក់ព័ន្ធ ប្រធានមន្ទីរបរិស្ថានខេត្តព្រះវិហារ និងប្រធានសហគមន៍តំបន់ការពារធម្មជាតិ **«ប្រាសាទឈើទាលកោង»** ត្រូវទទួលបន្ទុកអនុវត្តប្រកាសនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃអង្គារ ១៤រោច ខែ មាឃ ឆ្នាំច សំរឹទ្ធិស័ក ព.ស.២៥៦២
ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ០៥ ខែ មីនា ឆ្នាំ២០១៩

**រដ្ឋមន្ត្រី**

**សាយ សំអាល់**

កន្លែងទទួល
- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងមហាផ្ទៃ
- ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេច ឯកឧត្តម លោកជំទាវ ឧបនាយករដ្ឋមន្ត្រី
- រដ្ឋបាលខេត្តព្រះវិហារ
- ដូចប្រការ៦ «ដើម្បីអនុវត្ត»
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ

ផែនទី ព្រំប្រទល់សហគមន៍តំបន់ការពារធម្មជាតិព្រៃសាគរឈើនាលគោង ក្នុងដែនជម្រកសត្វព្រៃ " ព្រៃឡង់ "

ភូមិសាស្រ្តភូមិខ្នា ឃុំខ្នា ស្រុកជ័យសែន ខេត្តព្រះវិហារ ផ្ទៃដី៧២៨,៦២ហិកតា

យោងលិខិត : ប្រកាសលេខ ០.៥២ ..... ចុះថ្ងៃទី ៧ ខែ ..... ឆ្នាំ២០១៥ របស់ក្រសួងបរិស្ថាន




| ID | X | Y |
|---|---|---|
| 1 | 557245 | 1505801 |
| 2 | 557395 | 1505961 |
| 3 | 557469 | 1505969 |
| 4 | 557704 | 1506070 |
| 5 | 559342 | 1506208 |
| 6 | 561572 | 1506026 |
| 7 | 561703 | 1504569 |
| 8 | 561501 | 1503875 |
| 9 | 559948 | 1504011 |
| 10 | 557334 | 1505450 |

Map Coordinate System
Unit: meter
System: UTM, Zone 48
Datum: WGS 1984

មាត្រដ្ឋាន ១:២៥ ០០០